00755760

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 29 / 11 / 2011
ម៉ោង (Time/Heure) : 08:30
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

E118/4

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

# អង្គជំនុំជម្រះសាលាដំបូង-អនុស្សរណៈ

កាលបរិច្ឆេទ: ថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០១១

**ជូនចំពោះ:** ភាគីទាំងអស់នៃសំណុំរឿង ០០២

**ពី:** ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង

**ចម្លងជូន:** លោក/លោកស្រីចៅក្រមទាំងអស់នៃអង្គជំនុំជម្រះសាលាដំបូង, មន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង និងប្រធានផ្នែកគ្រប់គ្រងតុលាការ

**កម្មវត្ថុ:** ចម្លើយតបរបស់អង្គជំនុំជម្រះសាលាដំបូងទៅនឹងសំណើរបស់មេធាវីការពារក្ដីជនជាប់ចោទ អៀង សារី ដែលស្នើសុំពិនិត្យមើលឯកសារសម្ងាត់បំផុតនៅក្នុងសំណុំរឿង (**ឯកសារ** E118)

អនុស្សរណៈនេះធ្វើឡើងដោយយោងសំណើរបស់មេធាវីការពារក្ដីជនជាប់ចោទ អៀង សារី សុំពិនិត្យមើលឯកសារសម្ងាត់បំផុតនៅក្នុងសំណុំរឿង (ឯកសារ E118)។ ថ្វីបើមេធាវីការពារក្ដីជនជាប់ចោទ អៀង សារី មានសិទ្ធិពិនិត្យចំណងជើងត្រួសៗនៃឯកសារក្នុងប្រភេទខាងលើក្ដី ក៏ខ្លួនអះអាងថាសិទ្ធិនេះនៅពុំទាន់គ្រប់គ្រាន់នៅឡើយទេដើម្បីការពារសិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌។ សហព្រះរាជអាជ្ញាលើកឡើងថាសំណើសុំពិនិត្យមើលឯកសារសម្ងាត់បំផុតទាំងអស់ដោយពុំមានការបែងចែក និងដោយពុំគិតថាឯកសារទាំងនោះអាចត្រូវលើកយកមកបង្ហាញនៅសវនាការ គឺជាសំណើដែលគ្មានមូលដ្ឋានច្បាប់ត្រឹមត្រូវ និងគ្មានហេតុផលជាក់លាក់ (ឯកសារ E118/2)។ យ៉ាងណាមិញ សហព្រះរាជអាជ្ញាឯកភាពថាភាគីគួរអាចពិនិត្យមើលចំណងជើងពេញ

លេញ ឬ ចំណាងជើងក្នុងទម្រង់កោសលប់នៃឯកសារសម្ងាត់បំផុតទៅតាមការចាំបាច់។ មេធាវីការពារជនជាប់ចោទ អៀង ធីរិទ្ធ អះអាងថាឯកសារ និងរបាយការណ៍វេជ្ជសាស្ត្រ ពុំគួរគប្បីត្រូវបានបង្ហាញជាសាធារណៈឡើយ ហើយត្រូវដាក់ចំណាត់ថ្នាក់ជាឯកសារសម្ងាត់បំផុតឲ្យបានត្រឹមត្រូវ (ឯកសារ E118/1)។ មេធាវីការពារជនជាប់ចោទ ខៀវ សំផន បានយល់ស្របថា ឯកសារវេជ្ជសាស្ត្រគួរស្ថិតនៅជាឯកសារប្រភេទសម្ងាត់បំផុត (ឯកសារ E118/3)។

អង្គជំនុំជម្រះសាលាដំបូងបានពិនិត្យមើលឡើងវិញ ទៅលើខ្លឹមសារនៃឯកសារសម្ងាត់បំផុតក្នុងសំណុំរឿង ០០២។ ក្នុងចំណោមឯកសារសម្ងាត់បំផុតចំនួនប្រមាណ៤.៦០០ ឯកសារនៅក្នុងសំណុំរឿង០០២ មាន ៧៥០ ឯកសារ ជាឯកសារ និងរបាយការណ៍វេជ្ជសាស្ត្រ។ ក្នុងចំណោមឯកសារសម្ងាត់បំផុតចំនួន ៣.៨៥០ ឯកសារប្រមាណ ៥០០ ឯកសារ គឺជាឯកសារវាយតម្លៃអំពីតម្រូវការនៃវិធានការការពាររបស់អង្គភាពគាំពារសាក្សី និងអ្នកជំនាញ ចំណែកឯកសារចំនួន ១.៧០០ ជាពាក្យបណ្តឹង និងឯកសារចំនួន ១.៤០០ ជាពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីព្រមទាំងឯកសារភ្ជាប់មកជាមួយ។ មានតែឯកសារមួយចំនួនតូចប៉ុណ្ណោះ (ប្រមាណ៣០ឯកសារ) នៃឯកសារទាំងនេះត្រូវបានភាគីបញ្ជាក់ថាជាឯកសារពាក់ព័ន្ធនឹងសំណុំរឿង ០០២/០១ ដែលមានបញ្ជាក់នៅក្នុងបញ្ជីឈ្មោះសាក្សី ឯកសារ និងវត្ថុតាងដែលបានដាក់នៅក្នុងសំណុំរឿង ០០២ មកទល់នឹងពេលបច្ចុប្បន្ន។ មានឯកសារមួយក្នុងចំណោមឯកសារទាំងនេះគឺជាពាក្យបណ្តឹងរបស់ដើមបណ្តឹងរដ្ឋប្បវេណី ឬពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី។

ដើម្បីការពារសិទ្ធិរបស់ភាគី អង្គជំនុំជម្រះសាលាដំបូងសូមធ្វើការណែនាំដូចខាងក្រោម៖

*ឯកសារវេជ្ជសាស្ត្រ*

ឯកសារទាំងនេះនឹងនៅតែជាឯកសារសម្ងាត់បំផុតដើម្បីការពារសិទ្ធិឯកជនរបស់ជនជាប់ចោទម្នាក់ៗ។

*ការវាយតម្លៃអំពីហានិភ័យរបស់អង្គភាពគាំពារសាក្សី និងអ្នកជំនាញ*

អនុលោមតាមទម្លាប់អនុវត្តរបស់ខ្លួនមកទល់នឹងពេលបច្ចុប្បន្ន អង្គជំនុំជម្រះនឹងបន្តទទួលពាក្យសុំ និងសម្ភារៈផ្សេងៗពាក់ព័ន្ធនឹងវិធានការការពារក្នុងលក្ខណៈជាឯកសារសម្ងាត់បំផុត។ ជាទៀងទាត់អង្គ-

ភាពគាំពារសាក្សី និងអ្នកជំនាញបានធ្វើការវាយតម្លៃអំពីតម្រូវការនៃវិធានការការពារ ហើយក្នុងករណីច្រើនលើសលប់ អង្គភាពនេះរកពុំឃើញមូលហេតុគ្រប់គ្រាន់ដើម្បីផ្តល់វិធានការការពារឡើយ (ដូច្នេះអង្គភាពនេះពុំបានផ្តល់ការណែនាំអំពីវិធានការការពារដល់សាក្សី និងអ្នកជំនាញឡើយ)។ ការវាយតម្លៃអំពីតម្រូវការវិធានការការពារត្រូវបានដាក់បញ្ចូលទៅក្នុងសំណុំរឿង ក្នុងប្រភេទជាឯកសារសម្ងាត់បំផុតតាមសំណើរបស់ដើមបណ្តឹងរដ្ឋប្បវេណី ដោយហេតុថាការបង្ហាញព័ត៌មានសម្ងាត់នេះ (ហើយការចែកចាយបន្តទៅដល់ដើមបណ្តឹងរដ្ឋប្បវេណីចំនួនជិត៤.០០០នាក់ផ្សេងទៀត) អាចជាការទម្លាយព័ត៌មានផ្ទាល់ខ្លួន ឬបង្កើតឱ្យមានតម្រូវការនៃវិធានការការពារ ដែលជាប្រការពុំចាំបាច់។ ក្នុងករណីអង្គភាពគាំពារសាក្សី និងអ្នកជំនាញយល់ថា វិធានការការពារពាក់ព័ន្ធនឹងសាក្សី ឬដើមបណ្តឹងរដ្ឋប្បវេណីណាម្នាក់ដែលនឹងត្រូវកោះហៅចូលសវនាការជាការចាំបាច់នោះ អង្គជំនុំជម្រះនឹងជូនដំណឹងអំពីតម្រូវការនៃវិធានការការពារទៅសហមេធាវីនាំមុខ មេធាវីការពារក្តី និងសហព្រះរាជអាជ្ញាឱ្យបានទាន់ពេលវេលា។

*ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី និងពាក្យបណ្តឹង*

អង្គជំនុំជម្រះសាលាដំបូងកត់សម្គាល់ឃើញថាឯកសារភាគច្រើនលើសលប់ ដែលស្ថិតនៅក្នុងផ្នែកសម្ងាត់បំផុតនៃសំណុំរឿង គឺជាពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី និងពាក្យបណ្តឹង។ ហេតុផលកាលពីពេលដំបូងចំពោះការដាក់ចំណាត់ថ្នាក់ឯកសារទាំងនេះថាជាឯកសារសម្ងាត់បំផុត គឺសំដៅកំហិតការបង្ហាញឯកសារទាំងឡាយណាដែលពុំទាន់មានការសម្រេចលើសំណើសុំវិធានការការពារ។ នាពេលបច្ចុប្បន្ន មានបញ្ហាមួយចំនួនតូចប៉ុណ្ណោះដែលពុំទាន់បានសម្រេចពាក់ព័ន្ធនឹងវិធានការការពារចំពោះមុខអង្គជំនុំជម្រះសាលាដំបូងក្នុងករណីសំណុំរឿង ០០២ នេះ។ បន្ទាប់ពីបានពិគ្រោះយោបល់ជាមួយភាគី អង្គជំនុំជម្រះយល់ថាពុំមានហេតុផលណាមួយក្នុងការដាក់ចំណាត់ថ្នាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី និងពាក្យបណ្តឹងទាំងអស់ជាឯកសារសម្ងាត់បំផុតទៀតឡើយ។ តាមរយៈសេចក្តីណែនាំនេះ អង្គជំនុំជម្រះសាលាដំបូងបង្គាប់ឱ្យផ្នែកគ្រប់គ្រងតុលាការ កែប្រែចំណាត់ថ្នាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី និងពាក្យបណ្តឹងទាំងអស់ដែលស្ថិតនៅក្នុងផ្នែកសម្ងាត់បំផុតនៃសំណុំរឿង០០២ មកត្រឹមជាឯកសារសម្ងាត់វិញ។

*ឯកសារផ្សេងៗ*

នាពេលបច្ចុប្បន្ន ឯកសារមួយចំនួនតូចដែលនៅក្នុងផ្នែកសម្ងាត់បំផុតនៃសំណុំរឿងគឺអាចពុំស្ថិតនៅក្នុងប្រភេទឯកសារសម្ងាត់បំផុតឡើយ។ អង្គជំនុំជម្រះសាលាដំបូងកំពុងពិនិត្យមើលឡើងវិញលើឯកសារទាំងនេះដើម្បីសម្រេចថាតើ ខ្លួនគួររក្សាទុកចំណាត់ថ្នាក់ឯកសារខាងលើជាឯកសារសម្ងាត់បំផុត ឬកែប្រែមកជាឯកសារសម្ងាត់វិញ។ ភាគីនឹងបានទទួលការជូនដំណឹងអំពីលទ្ធផលនៃការពិនិត្យមើលឡើងវិញនេះនៅពេលសមស្រប។

*ឯកសារនៅក្នុងផ្នែកសម្ងាត់បំផុតដែលពុំទាន់ទទួលបានការបញ្ជាក់ថាជាឯកសារពាក់ព័ន្ធនឹងសំណុំរឿង ០០២/០១ មកទល់នឹងពេលបច្ចុប្បន្ន*

អង្គជំនុំជម្រះសាលាដំបូងបានឯកភាពថាព័ត៌មានបន្ថែមគួរត្រូវបានផ្តល់ទៅភាគី *តាមរយៈ* ចំណងជើងលម្អិតជាងមុននៃឯកសារជាច្រើនដែលរក្សាចំណាត់ថ្នាក់ជាឯកសារសម្ងាត់បំផុត បន្ទាប់ពីមានការកែប្រែចំណាត់ថ្នាក់ខាងលើ។ ដើម្បីសម្រួលកិច្ចការនេះ អង្គជំនុំជម្រះកំពុងពិនិត្យមើលឡើងវិញលើចំណងជើងនៃឯកសារក្នុងផ្នែកសម្ងាត់បំផុតនៃសំណុំរឿង និងដាក់ចំណងជើងច្បាស់លាស់ និង/ឬ ចំណងជើងកោសលប់ដែលបញ្ជាក់អំពីខ្លឹមសារនៃឯកសារទាំងនោះ ជំនួសឲ្យចំណងជើងត្រួសៗ។ ភាគីនឹងទទួលបានការជូនដំណឹងនៅពេលអង្គជំនុំជម្រះអនុវត្តកិច្ចការនេះចប់សព្វគ្រប់។ អង្គជំនុំជម្រះសាលាដំបូងសូមរំឭកថាភាគីដែលស្នើសុំបង្ហាញឯកសារនៅពេលក្រោយៗ គឺត្រូវបំពេញលក្ខខណ្ឌខ្ពស់បំផុតក្នុងការបង្ហាញថាឯកសារទាំងនេះពុំអាចរកបាននៅក្នុងពេលវេលាកំណត់ ទោះបីជាខ្លួនបានព្យាយាមដោយយកចិត្តទុកដាក់ត្រឹមត្រូវក៏ដោយ ហើយការដាក់ភស្តុតាងយឺតយ៉ាវនេះគឺដើម្បីប្រយោជន៍នៃយុត្តិធម៌។ នេះគឺជាចម្លើយតបជាផ្លូវការរបស់អង្គជំនុំជម្រះសាលាដំបូងទៅនឹងសំណើសុំឯកសារ E118។